# ធម្មកថា

## របស់ព្រះតេជព្រះគុណបណ្ឌិត ហុក-សាវណ្ណ អំពីព្រះពុទ្ធសាសនាពោលថា កំណើតរបស់មនុស្ស ប្រសើរជាងកំណើតសត្វតិរច្ឆាន

Website: www.hoksavann.org

ថ្ងៃទី៦ ធ្នូ ២០០៤

ពាក្យថាមនុស្សតាមស័ព្ទបាលីប្រែថា អ្នកដឹងខុសត្រូវ មកពីវិគ្គហៈថា ការណាការណំ មនតិ ជានាតីតិ មនុស្សោ (សត្តវិសេសោ) ប្រែថា ( សត្វពិសេស) អ្នកដឹងហេតុគួរនិងហេតុមិនគួរ ហៅថាមនុស្ស ។ បានសេចក្តីថា បញ្ញត្តិសព្ទថា មនុស្សសំដៅយកសត្វពិសេសមួយពួក ដែលមានការរិកចំរើនខាងគំនិតបញ្ញា គឺមានធម្មសញ្ញាប្រសើរជាងសត្វតិរច្ឆាន ។ សត្វតិរច្ឆានទោះបីរស់នៅច្រើនតំណ តពីមេបាវាក៏ដោយ ក៏ពុំអាចរីកចំរើនខាងគំនិតបញ្ញាឡើយ ដូចសត្វចាបសត្វកណ្ដៀរ ធ្វើសំបុកធ្វើដំបូក មេបាវាធ្វើយ៉ាងណា កូនចៅវាក៏នៅតែធ្វើយ៉ាងនោះ, វាពុំមានគំនិតបញ្ញាឆ្លៃឲ្យប្រសើរជាងនេះទៀតឡើយ គឺវារស់នៅតាមសភាវគតិ ។ ចំណែកមនុស្សអាចរីកលូតលាស់ខាងចំណេះដឹងគ្រប់យ៉ាង និងចរិយាសម្បត្តិថ្លៃថ្នូរ បើគេបានសិក្សាអប់រំតាមផ្លូវល្អ ។ មនុស្សមានអាយុវែងជាងសត្វតិរច្ឆានភាគច្រើន ហើយមានជីវិតប្រសើរ ព្រោះមនុស្សអាចសាងសុភមង្គលឲ្យដល់ខ្លួន ។ តាមរូបវិទ្យា ខួរក្បាលមនុស្សមានសក្ដានុភាពអាចបង្កើតសតិបញ្ញាស្មារតីបានយ៉ាងល្អប្រសើរ ។ សង្គមមនុស្សតាំងពីចាប់ផ្ដើមប្រវត្តិសាស្ត្ររហូតមកដល់បច្ចុប្បន្ននេះ បានរីកចំរើនគ្រប់វិស័យ ទាំងផ្នែកសម្ភារៈ ទាំងផ្នែកសតិបញ្ញា និងផ្នែកសីលធម៌ ។ ព្រះពុទ្ធសំដែងថា ការកើតមកជាមនុស្សជាការក្រ ព្រោះបើប្រៀបធៀបជាមួយសត្វតិរច្ឆាន ចំនួនមនុស្សនៅតែមានចំនួនតិចជាងសត្វតិរច្ឆាន ។ ចំពោះមនុស្សទោះបីកើតមកពីធាតុ៤ដូចគ្នា មានអាយតនៈដូចគ្នាក៏ដោយ ប៉ុន្តែមានទម្រង់រូបរាងកាយនិងចិត្តគំនិតផ្សេងៗពីគ្នា ទៅតាមឧបនិស្ស័យនិងការអប់រំរបស់ខ្លួន ។ មនុស្សគ្រប់ជនជាតិមានចិត្តគំនិតមួយដូចគ្នា គឺចង់បានសេចក្ដីសុខ ។ ត្រង់នេះហើយបានជាព្រះពុទ្ធសំដែង កុំឲ្យមនុស្សបៀតបៀនគ្នា ព្រោះមនុស្សសុទ្ធតែស្រឡាញ់សេចក្ដីសុខដូចគ្នាទាំងអស់ ។ បើមនុស្សបៀតបៀន គេនឹងត្រូវទទួលផលជាទុក្ខតបវិញ ។ ព្រះពុទ្ធបានចែកមនុស្សជា៤ប្រភេទ ទៅតាមអំពើដែលគេបានធ្វើ គឺពុំមែនចែកទៅតាមរូបរាងកាយ ទ្រព្យសម្បត្តិ ជាតិត្រកូល កិត្តិយសទេ ។ មនុស្ស៤ប្រភេទនោះគឺ មនុស្សោ រូបរាងកាយជាមនុស្ស អំពើប្រព្រឹត្តប្រកបដោយធម៌របស់មនុស្ស គឺមនុស្សធម៌ពុំបៀតបៀនអ្នកដទៃ ជាពិសេសជាអ្នកមានសីល៥, មនុស្សបេតោ រូបរាងកាយជាមនុស្ស ប៉ុន្តែអំពើប្រព្រឹត្តធ្វើឲ្យអ្នកដទៃខាតបង់ទ្រព្យសម្បត្តិ កំណាញ់ពុំធ្វើទាន ជួយសង្គ្រោះអ្នកដទៃដែលក្រីក្រជាងខ្លួនជាដើម ស្លាប់ទៅកើតជាប្រេត, មនុស្សនេរយិកោ រូបរាងកាយជាមនុស្ស ប៉ុន្តែអំពើប្រព្រឹត្តកាប់សម្លាប់អ្នកដទៃជាដើម មនុស្សប្រភេទនេះស្លាប់ទៅធ្លាក់នរក, មនុស្សតិរច្ឆានោ រូបរាងកាយជាមនុស្ស អំពើប្រព្រឹត្តពុំដឹងគុណមាតាបិតាជាដើម មនុស្សប្រភេទនេះស្លាប់ទៅកើតជាសត្វតិរច្ឆាន ។ មនុស្សមួយប្រភេទទៀតហៅថា មនុស្សទេវោ ប្រែថា មនុស្សទេវតា គឺជាមនុស្សហិរិឱត្តប្បៈខ្មើមបាប ខ្លាចបាប ពុំហ៊ានប្រព្រឹត្តធ្វើ គឺជាអ្នកប្រព្រឹត្តតាមទេវធម៌ ។ ពិសេសជាមនុស្សដ៏ខ្ពង់ខ្ពស់មួយប្រភេទទៀត គឺវិសុទ្ធមនុស្ស ឬវិសុទ្ធិទេព ប្រែថាមនុស្សបរិសុទ្ធឬទេវតាបរិសុទ្ធ បានដល់ព្រះអរហន្តមានព្រះពុទ្ធជាដើម ព្រោះលោកកំចាត់បាបអស់ហើយ ។

ព្រះសម្ពុទ្ធវិនិច្ឆ័យមនុស្សខ្ពង់ខ្ពស់និងថោកទាបដោយសារអំពើរបស់គេ ។ ថ្ងៃមួយ ព្រះសម្ពុទ្ធបាននិមន្តទៅបិណ្ឌបាត្រ ព្រះអង្គបានឈប់នៅមុខផ្ទះព្រាហ្មណ៍ម្នាក់ ព្រាហ្មណ៍បានឃើញហើយ និយាយទៅកាន់ព្រះពុទ្ធដោយពាក្យពុំសមរម្យថា ណែសមណៈតូចទាប ណែសមណៈថោកទាប យើងមិនដាក់បាត្រទេ សូមនិមន្តទៅទៀតចុះ ។ ពេលនោះព្រះសម្ពុទ្ធត្រាស់ថា ម្នាលព្រាហ្មណ៍ អ្នកឯងដឹងបុគ្គលដែលថោកទាបនឹងធម៌ដែលធ្វើឲ្យបុគ្គលថោកទាបហើយឬនៅ ? ព្រាហ្មណ៍ឆ្លើយតប ខ្ញុំព្រះអង្គពុំបានដឹងទេ ។ ព្រះអង្គត្រាស់ថា ម្នាលព្រាហ្មណ៍ ទំនាបនិងកំពស់របស់មនុស្សពុំមែនស្ថិតនៅលើរូបរាងកាយជាតិត្រកូលទ្រព្យសម្បត្តិយសស័ក្តិទេ តែត្រូវស្ថិតនៅលើកម្ម គឺអំពើដែលគេបានប្រព្រឹត្ត បុគ្គលណាប្រព្រឹត្តល្អដោយកាយវាចានិងចិត្ត បុគ្គលនោះជាបុគ្គលខ្ពង់ខ្ពស់ ។ បុគ្គលណាប្រព្រឹត្តអាក្រក់ដោយកាយវាចានិងចិត្ត បុគ្គលនោះជាបុគ្គលថោកទាប ។ ពេលនោះ ព្រាហ្មណ៍ក៏កើតចិត្តជ្រះថ្លាចំពោះព្រះអង្គ ដោយបានស្ដាប់ពាក្យពិតនេះ ។ ពុទ្ធសាសនាពោលថា មនុស្សនឹងមានវាសនាអនាគតទៅជាយ៉ាងណានោះ អាស្រ័យឧបនិស្ស័យពីមុនមកផង អាស្រ័យកម្មផលដែលខ្លួនប្រព្រឹត្តក្នុងបច្ចុប្បន្នផង ។ មនុស្សតែងមានគុណសម្បត្តិផងគុណវិបត្តិផង ចំពោះរឿងនេះព្រះពុទ្ធសំដែងជាស់តឿនថា បើរៀនហាត់ នេះអំពើអាក្រក់ដែលជាគុណវិបត្តិឲ្យថយចុះរាល់ថ្ងៃ ហើយរៀនហាត់បណ្ដុះអំពើល្អ ដែលជាគុណសម្បត្តិឲ្យបានច្រើនរាល់ថ្ងៃ នោះគុណសម្បត្តិនឹងកើតមានកាន់តែច្រើនឡើង មនុស្សនោះលោកហៅថា កល្យាណបុថុជ្ជន រស់នៅមានប្រយោជន៍ដល់សង្គមមនុស្ស បើស្លាប់ទៅគេនៅតែសោកស្ដាយ ។៚